ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិជ្ជា

# ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ



រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ រដ្ឋបាលជលផល

ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយៈ លោក ជិន ដា**

**រដ្ឋបាលជលផល**

ទូរស័ព្ទលេខៈ ០២៣ ៩៩៦ ៣៨០ ឬ ០១១៩៩០៩៩០

អ៊ីម៉ែលៈ smallfish@online.com.kh

**កាលបរិច្ឆេទៈ ខែ កក្កដា ឆ្នាំ ២០០៦**

DRAFT

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា(បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍ អន្តរជាតិ តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹង ស្ថាប័ន និង ប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វ ផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជ រដ្ឋាភិបាលតាម រយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង ។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Suject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋាន ជំនាញ នានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេង១ទៀត ។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារ គោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និង ភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មី១ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករ ដែលរស់នៅក្នុង តំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅ មូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បី ធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រ ចតុកោណ របស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម ។

**រដ្ឋមន្ត្រី**

DRAFT

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយ បញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់អោយមន្ត្រីផ្សព្វផ្សាយផ្ទេរ បច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបម្រើការនៅក្នុង វិស័យអភិវឌ្ឍន៏កសិកម្ម នៅតាមមូលដ្ឋានប្រើប្រាស់ ។បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបម្រើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈប្រភពជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុក នូវព័ត៌មានសំខាន់ៗ របស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោមៈ

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាត ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

DRAFT

# ការចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ


១. ការពិពណ៌នា.......................................... វែវ្យរ1 ញ្ញឹកមារក ឡ្យត ដថេិនដេ។

២. គោលការណ៍បច្ចេកទេស.......................................... ២

២.១- ហេតុអ្វីយើងចាំបាច់ចិញ្ចឹមត្រី ?.......................................... ២

២.២- ការជ្រើសរើសទីកន្លែង សម្រាប់ការអភិវឌ្ឍន៍ចិញ្ចឹមត្រី.......................................... ៣

*២.២.១ - លក្ខណៈប្រភពទឹក*.......................................... ៣

*២.២.២ - លក្ខណៈតំបន់អភិវឌ្ឍន៍ការចិញ្ចឹមត្រី*.......................................... ៣

*២.២.៣ - លក្ខណៈសេដ្ឋកិច្ចសង្គម*.......................................... ៣

២.៣- របៀបជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី.......................................... ៣

២.៤- ការជ្រើសរើសទីតាំងជីកស្រះ.......................................... ៤

*២.៤.១ - ការជ្រើសរើសទីតាំង*.......................................... ៤

*២.៤.២ - គុណភាពដី សម្រាប់ស្រះចិញ្ចឹមត្រី*.......................................... ៥

*២.៤.៣ - របៀបជីកស្រះចិញ្ចឹមត្រី*.......................................... ៦

២.៥- ការរៀបចំស្រះមុនពេលដាក់ត្រីចិញ្ចឹម.......................................... ៧

*២.៥.១ - ការស្តារភក់បាតស្រះ*.......................................... ៧

*២.៥.២ - ការប្រើប្រាស់កំបោរ និងជី*.......................................... ៨

*២.៥.៣ - ការត្រួតពិនិត្យគុណភាពទឹក*.......................................... ១០

២.៦- ការជ្រើសរើសកូនត្រីពូជដាក់ចិញ្ចឹម.......................................... ១១

២.៧- ការដឹកជញ្ជូនកូនត្រី.......................................... ១៤

២.៨- ការដាក់កូនត្រីចិញ្ចឹម.......................................... ១៥

២.៩- ប្រភេទចំណី និងរបៀបដាក់ចំណី.......................................... ១៦

២.១០- ប្រភេទជី និងរបៀបដាក់ជី.......................................... ១៨

២.១១- ការគ្រប់គ្រងស្រះ.......................................... ២០

*២.១១.១ - ការត្រួតពិនិត្យគុណភាពទឹកស្រះ*.......................................... ២០

*២.១១.២ - កត្តសត្រួតពិនិត្យគុណភាពទឹក*.......................................... ២២

*២.១១.៣ - ការត្រួតពិនិត្យ កូនត្រីពូជទីឡាព្យ៉ា*.......................................... ២៣

*២.១១.៤ - ការព្យាយាមត្រួតពិនិត្យមើលស្រះចិញ្ចឹមត្រី*.......................................... ២៣

*២.១១.៥ - វិធានការការពារជម្ងឺត្រី*.......................................... ២៤

២.១២- ការប្រមូលផលត្រី.......................................... ២៤

២.១៣- ការវិភាគសេដ្ឋកិច្ច.......................................... ២៥

៣. វិធីសាស្ត្រផ្សព្វផ្សាយ.......................................... វែវ្យរ1 ញ្ញឹកមារក ឡ្យត ដថេិនដេ។

៣.១- វិធីសាស្ត្រអនុវត្ត.......................................... ២៦


DRAFT